សារព័ត៌មាន

# ខ្មែរម្ចាស់ស្រុក

Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី០២ លេខ២៣៥ ចេញផ្សាយថ្ងៃ ពុធ ទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៨

## លទ្ធផលនៃការបោះឆ្នោតដែលប្រកាសជាផ្លូវការដោយ គ.ជ.ប មិនត្រូវបានគណបក្សប្រឆាំងទទួលស្គាល់ជាដាច់ខាត



លោក សម រង្ស៊ី មេដឹកនាំគណបក្សដ៏ខ្លាំងនៃប្រទេសកម្ពុជា



ទេព នីថា និង អ៊ឹម សួស្ដី មេដឹកនាំ គ.ជ.ប ដែលមានឈ្មោះកាន់តែអាក្រក់

**ដោយ : ហង្ស ឧត្ដម**

លោក *សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ី បានមានប្រសាសន៍ឱ្យដឹងជាសាធារណៈតាមរយៈកម្មវិធីពន្លឺភ្លើងទៀនថា *"យើងសុំប្រកាសសាជាថ្មីម្ដងទៀតនៅក្នុងថ្ងៃនេះថាគណបក្សសមរង្ស៊ីនិងគណបក្សសិទ្ធិមនុស្សមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដែល គ.ជ.ប ត្រូវប្រកាសជាផ្លូវការ*

តទៅទំព័រ៤ យ

## គណបក្សសមរង្ស៊ីស្នើសម្ដេចឪធ្វើជាព្រះប្រធានក្នុងការដោះស្រាយបញ្ហាជាមួយសៀម

**ដោយ : ស្សាវរីយ៍**

គណបក្សសម រង្ស៊ី បានសរសេរលិខិត ស្នើសម្ដេចឪ ព្រះ*នរោត្តម សីហនុ* ព្រះមហាវីរក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាធ្វើជាព្រះប្រធានចលនាស្នេហាជាតិ ឬជាព្រះរាជយោបល់ដល់រដ្ឋាភិបាលក្នុងការដោះ

តទៅទំព័រ៣ គ



សម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រនៃកម្ពុជា

## ប្រជាពលរដ្ឋនៅតំបន់បឹងកក់ទាមទារឱ្យក្រុមហ៊ុនចេញមុខមកដោះស្រាយបញ្ហាសំណងតាមតម្លៃទីផ្សារដោយផ្ទាល់



លំនៅដ្ឋានប្រជាពលរដ្ឋនៅបឹងកក់កំពុងទឹកជន់លិចលង់



ឧកញ៉ា ឡោ ម៉េងឃីន និងប្រពន្ធឈ្មោះ យាយភូ



លោក កែប ជុតិមា ចៅហ្វាយក្រុងភ្នំពេញដែលមានឈ្មោះមិនសុវណ្ណ



ដោយសារក្រុមហ៊ុនបូមខ្សាច់ដាក់បឹងកក់ធ្វើឱ្យលិចលង់ផ្ទះប្រជាពលរដ្ឋ

**ដោយ : យុទ្ធ ពន្យ**

ប្រជាពលរដ្ឋដែលកំពុងរស់នៅតំបន់បឹងកក់បានបញ្ចេញប្រតិកម្មយ៉ាងកងរំពងដោយទាមទារឱ្យបញ្ឈប់ការបូមខ្សាច់ដាក់បឹងកក់និងតម្រូវឱ្យក្រុមហ៊ុនចេញមុខមកដោះស្រាយសំណងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋតាមតម្លៃទីផ្សារនិងមិនចាំបាច់តាមរយៈសាលាក្រុងភ្នំពេញនោះទេ។

តទៅទំព័រ៤ ម

## ម៉ឹង សំផន ជាអតីតទាហានរត់ចោលជួរ ?



នាយឧត្ដមសេនីយ៍ផ្កាយមាស៤ ម៉ឹង សំផន



អតីតសមមិត្តនារី ម៉ែន សំអន

**ដោយ : វិសាល**

លោក *ម៉ឹង សំផន* ដែលបច្ចុប្បន្នជានាយឧត្ដមសេនីយ៍ផ្កាយមាស៤ និងមានឋានៈជារដ្ឋលេខាធិការក្រសួងការពារជាតិនោះត្រូវបានលិខិតអនាមិកមួយសរសេរបកអាក្រាតថា *"ម៉ឹង សំផន មានអតីតភាពជា*

តទៅទំព័រ២ ស

## ងួន ញ៉ិល, ចៅង ខុន បោករាស្ត្រយកសន្លឹកឆ្នោតលេចឱ្យឃើញច្បាស់លាក់លែងជិតនៅខេត្តកំពង់ធំ



លោក ងួន ញ៉ិល



លោក ចៅង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍

**ដោយ : ត.អរពិន្ទ**

អ្វីដែលធ្វើឱ្យគេមើលឃើញយ៉ាងច្បាស់ថា សកម្មភាពដឹកនាំរបស់គណបក្សប្រជាជន*ហ៊ុន សែន* មិនមែនធ្វើដើម្បីប្រយោជន៍ជួយប្រជារាស្ត្រនិងប្រទេសជាតិពិតប្រាកដនោះ ត្រូវបានគេដឹងដូចជាភស្តុតាងបង្ហាញថ្មីៗ

តទៅទំព័រ២ ឈ

## សមរង្ស៊ីចេញទៅក្រៅប្រទេសល្ងាចថ្ងៃនេះ

**ដោយ : រតនះ**

លោក*សម រង្ស៊ី* ប្រធានគណបក្សសម រង្ស៊ី នឹងចេញដំណើរទៅក្រៅប្រទេស នៅល្ងាចថ្ងៃពុធនេះហើយ ដើម្បីនាំយកឯកសារ ភស្តុតាង ស្ដីពីភាពមិនប្រក្រតី នៃការបោះឆ្នោតទៅប្ដឹងប្រធានសហគមន៍អឺរ៉ុប អង្គការសហប្រជាជាតិ

តទៅទំព័រ៣ ហ

## សម្ដេចក្រុមព្រះយាងចូលអន្ទាក់ ហ៊ុន សែន



ទ្រង់ នរោត្តម រណឫទ្ធិ មេបក្សដ៏មហាយ៉ាប់ផុតលេខ



នាយករដ្ឋមន្ត្រី ហ៊ុន សែន

**ដោយ : សច្ចះ**

ឧត្ដមសេនីយ៍ អតីតអ្នកតស៊ូនៅជាយដែន ប្រឆាំងនឹងចោរយួនឈ្លានពានខ្មែរ កាលពីក្នុងទសវត្សរ៍១៩៨០ បានឱ្យដឹងថាសម្ដេចក្រុមព្រះ អតីតប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច កំពុងតែយាងចូលព្រះអន្ទាក់នាយករដ្ឋ

តទៅទំព័រ២ ជ

ស្រូវទុំ កំរងកែវ

ភោជនីយដ្ឋាន **កំរងកែវ** អតីតភោជនីយដ្ឋាន **ស្រូវទុំ** ឥឡូវនេះបានបើកឡើងវិញហើយ ដោយប្ដូរឈ្មោះថា **កំរងកែវ** ដោយប្ដូរទាំងចៅកែ។

លោក មាស គន្ធី ដែលជាអតីតចៅកែភោជនីយដ្ឋាន **ស្រូវទុំ** ត្រូវបានផ្លាស់ប្ដូរដោយចៅកែថ្មីដែលមានជំនាញពិសេសល្អលើសចៅកែចាស់ (ស្រូវទុំ) ទ្វេដង ពីព្រោះចៅកែថ្មី និងចុងភៅសុទ្ធតែមានបទពិសោធយូរឆ្នាំ និងមានជំនាញច្បាស់លាស់។

អាស្រ័យហេតុនេះ សូមអញ្ជើញភ្ញៀវទាំងអស់មកភ្លក្សរស់ជាតិដែលជាស្នាដៃរបស់ចៅកែ និងចុងភៅថ្មី និងមានការរៀបចំយ៉ាងពិសេសសម្រាប់ភ្ញៀវទាំងអស់ដែលបានអញ្ជើញមកពិសានៅភោជនីយដ្ឋានយើងខ្ញុំ។

**បញ្ជាក់** : ចំពោះភ្ញៀវដែលអញ្ជើញមកពិសានៅភោជនីយដ្ឋាន **កំរងកែវ** យើងខ្ញុំដោយភ្ជាប់ជាមួយនឹងប័ណ្ណជូនដំណឹងក្នុងសារព័ត៌មានខ្មែរម្ចាស់ស្រុកនេះ យើងខ្ញុំនឹងបញ្ចុះតម្លៃជូន១០%។

អាស័យដ្ឋាន ផ្ទះលេខ៤២ ផ្លូវ២៨៩ កែងសាលាទួលគោក "ពៅអុំ"

ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្ដំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្ដី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បៀត ព្យាបាល យ៉ាងស័ក្ដិសិទ្ធិ។

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្ពាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : **012 363 331, 016 719 616, 012 801 863, 016 719 613**

*បរិយាយថ្ងៃនេះ*

## នាយករដ្ឋមន្ត្រីសៀមខ្លាចធ្លាក់ចេញពីតំណែង ឯនាយករដ្ឋមន្ត្រីខ្មែរក៏ខ្លាចធ្លាយរឿងកិច្ចសន្យារកស៊ីសម្ងាត់ជាមួយសៀមដែរ

**ដោយ : ហង្ស ច្រាថ្លា**

ខណៈពេលដែលស្ថានការណ៍នយោបាយនៅទីក្រុងបាងកកក៏ដូចជាតាមបណ្ដាខេត្តនានានៅប្រទេសសៀមកំពុងរីករាលខ្លាំងដោយមានចលនាបាតុកម្មប្រឆាំងទាមទារឱ្យនាយករដ្ឋមន្ត្រីសៀម សាម៉ាក់ ស៊ុនដារ៉ាវេត ជាមនុស្សរងការចោទប្រកាន់ថាជាកូនអុកអតីតនាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណាវ៉ា

តទៅទំព័រ៤ ក

**តមកពីទំព័រ១ ឈ**

នៅក្រោយការបោះឆ្នោតនៅស្រុកបារាយណ៍ ខេត្តកំពង់ធំ។ នៅទីនោះគណបក្សប្រជាជនរបស់ *ហ៊ុន សែន* បានបង្ហាញចេញនូវអត្តចរិតនៃការគិតផលប្រយោជន៍របស់ខ្លួនជាធំ និងពុំមែនគិតដល់អនាគតរបស់ប្រជារាស្ត្រ និងប្រទេសកម្ពុជានោះទេ។

នោះគឺក្នុងស្រុកបារាយណ៍នៃខេត្តកំពង់ធំ ដែលជាស្រុកកំណើតរបស់លោក *ងួន ញ៉ិល* អនុប្រធានទី១ នៃសភាជាតិ និងជាសមាជិកការិយាល័យនយោបាយរបស់គណបក្សប្រជាជន បើទោះបីជា *ហ៊ុន សែន* ហែហមដោយពួកមន្ត្រីជាបរិវារក្នុងរដ្ឋាភិបាលទៅប្រកាសផ្តល់អំណោយសន្យាសាងសង់សាលារៀនជូនប្រជារាស្ត្រកាលមុនបោះឆ្នោតក៏ដោយក៏នៅក្រោយការបោះឆ្នោតថ្មីៗ គណបក្សនេះបានទុកចោលនូវការសន្យារបស់ខ្លួន។

គេនៅចាំបានថា នៅអំឡុងខែមីនា ឆ្នាំ២០០៨ ពេលទៅបង្ហាញខ្លួនឆ្លៀតបន្លំឃោសនាយកមុខសម្រាប់ខ្លួនឯងរបស់ *ហ៊ុន សែន* ផង របស់គណបក្សប្រជាជននៅវត្តទេពនិមិត្តក្នុងស្រុកបារាយណ៍ផងនោះ *ហ៊ុន សែន* បានប្រកាសថា "*ជូនតាមសំណើ សាលារៀនមួយខ្នងដែលមាន១២បន្ទប់*"។

ពាក្យអស់ទាំងនេះត្រូវប្រជារាស្ត្រនៅតែចងចាំ ហើយអ្វីដែលគេដឹងថា នោះជាការសន្យាបោកប្រាស់ប្រជារាស្ត្រដើម្បីចង់បានសន្លឹកឆ្នោតនៅត្រង់ថានៅពេលដែលគណបក្សប្រជាជន *ហ៊ុន សែន* បានចាញ់គណបក្សសមរង្ស៊ីដល់ទៅ៤០០សម្លេងនៅឃុំមួយនោះក៏ស្រាប់តែគណបក្សប្រជាជនជាពិសេសរដ្ឋាភិបាល *ហ៊ុន សែន* ទាំងនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ខ្លួនឯងបានលេបកំហាកដែលខ្លួនបានស្តោះចំពោះមុខប្រជារាស្ត្រនោះ។ ពោលគឺរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* បានសម្តែងការខឹងសម្បារ ហើយប្រកាសឱ្យដឹងថានឹងមិនស្ថាបនាសាលារៀន១ខ្នង១២បន្ទប់សម្រាប់ជាគ្រឹះស្ថានសិក្សាឱ្យកូនប្រជារាស្ត្រខ្មែរនៅទីនោះបានសិក្សានោះទេ។

ការថ្លែងរបស់ *ហ៊ុន សែន* បែបនេះក៏មាន*ថោងខុន*រដ្ឋមន្ត្រីក្រសួងទេសចរណ៍បង្ហាញមុខនៅទីនោះដែរ មិនមែនត្រឹមតែលោក *ងួន ញ៉ិល* អនុប្រធានទី១ នៃសភាជាតិ ជាមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជននោះទេ។ ហើយពាក្យសន្យារបស់ *ហ៊ុន សែន* ថា នឹងសាងសង់សាលារៀន១ខ្នង១២បន្ទប់ឱ្យកូនចៅប្រជារាស្ត្រនៅទីនោះ ក៏ក្លាយទៅជាការឃោសនាប្រាថ្នារកសន្លឹកឆ្នោតយ៉ាងច្បាស់ក្រឡែត។ គ្រាន់តែគណបក្សប្រជាជនបានចាញ់ឆ្នោតចំពោះមុខគណបក្សសមរង្ស៊ីសោះ ទាំង *ហ៊ុន សែន* ក្នុងនាមជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលគណបក្សប្រជាជន និងមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនបាននាំគ្នាខឹងដាច់ក្បាលដាច់កន្ទុយហើយដកចោលនូវគម្រោងនៃការស្ថាបនាសាលារៀននៅទីនោះ។

ហ្នឹងហើយជាតឹកតាងបង្ហាញប្រាប់ប្រជារាស្ត្រ ក៏ដូចជាពួកអ្នកសង្កេតការណ៍ ជាពិសេសម្ចាស់ជំនួយស្គាល់ក្រយៅ ក៏ដូចជាក្រឡានយោបាយពិតប្រាកដរបស់គណបក្សប្រជាជន *ហ៊ុន សែន* ដឹកនាំប្រទេសមិនមែនដើម្បីជួយកូនចៅប្រជារាស្ត្រ និងជួយស្ថាបនាប្រទេសជាតិនោះទេ។ ប៉ុន្តែផ្ទុយទៅវិញគណបក្សប្រជាជន *ហ៊ុន សែន*ធ្វើអ្វីៗដើម្បីគោលដៅផលប្រយោជន៍នៃការរក្សាអំណាចរបស់ខ្លួនងាយស្រួលនឹងប្រើអំណាចមុខនាទីតំណែងកិបកេងប្រវ័ញ្ចទ្រព្យសម្បត្តិធនធានជាតិតាមរយៈអំពើពុករលួយដើម្បីបង្កើនគំនរទ្រព្យបក្ខពួកខ្លួន។

ការដែលគណបក្សប្រជាជន *ហ៊ុន សែន* លុបចោលនូវការសន្យារបស់ខ្លួនថានឹងសាងសង់សាលារៀនមួយខ្នងឱ្យកូនចៅប្រជាពលរដ្ឋបានចូលរៀននោះបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថានេះជាការសងសឹកនយោបាយរបស់គណបក្សប្រជាជន *ហ៊ុន សែន* ចំពោះមុខប្រជារាស្ត្រ។ គឺថាពុំមែនគោលការណ៍ប្រជាធិបតេយ្យសេរី នៃការគោរពឆន្ទៈរបស់ប្រជារាស្ត្រនោះទេ ជាបំណងធំរបស់គណបក្សប្រជាជន *ហ៊ុន សែន*។ ប៉ុន្តែគឺគោលដៅអំណាច ដោយពួកគេមិនខ្លាចនឹងអនុវត្តការសងសឹកនយោបាយចំពោះប្រជារាស្ត្រដោយបញ្ឈឺប្រជារាស្ត្រថាស្រេចតែគេមិនចង់សាងសង់សាលារៀន បើទោះបីជាគេសន្យាដោយសារចង់បានសន្លឹកឆ្នោតពីប្រជារាស្ត្រហើយប្រជារាស្ត្រមិនបានផ្តល់សន្លឹកឆ្នោតឱ្យគណបក្សប្រជាជន *ហ៊ុន សែន*។

គណបក្សប្រជាជនបានសម្រេចធ្វើការសងសឹកដោយកំហឹងចំពោះប្រជារាស្ត្រដែលមិនព្រមធ្វើការបោះឆ្នោតឱ្យខ្លួនមិនមែនធ្វើឱ្យបាក់មុខមាត់ត្រឹមតែពួកអាជ្ញាធរមូលដ្ឋានថ្នាក់ភូមិ ឃុំ ស្រុក និងថ្នាក់ដឹកនាំខេត្តនៃគណបក្សប្រជាជនប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ធ្វើឱ្យបាក់មុខមាត់ដល់ *ងួន ញ៉ិល* ដែលសុទ្ធតែជាបេក្ខជនសមាជិកសភាគន្លឹះនៅខេត្តកំពង់ធំ។ ជាពិសេសនោះទៅទៀតវាក៏ធ្វើឱ្យបាក់មុខមាត់ទាំង *ហ៊ុន សែន* នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលគណបក្សប្រជាជនផង។

នយោបាយសងសឹកដោយយកប្រជារាស្ត្រជាគោលដៅបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថាគោលការណ៍នយោបាយរបស់គណបក្សនេះមិនមែនដើម្បីប្រជារាស្ត្រទេ។ ហើយអ្វីៗអស់ទាំងនេះ ក៏មិនមែនកើតមានតែនៅស្រុកបារាយណ៍ នៃខេត្តកំពង់ធំនោះឡើយ ។វាក៏បានកើតមាននៅឃុំ ស្រុក ខេត្តដទៃទៀតយ៉ាងច្រើនក្នុងប្រទេសដែរ ជាពិសេសនៅតាមខេត្ត-ក្រុងណាដែលគណបក្សប្រជាជនបានចាញ់សន្លឹកឆ្នោត។

ការបាក់មុខរបស់ *ហ៊ុន សែន* នោះគឺ បើទោះបីជាគាត់បានប្រើប្រាស់ *សុក ផេង* ជាមនុស្សឱកាសនិយមរត់ចេញពីគណបក្សសមរង្ស៊ីចូលសុំតំណែងគណបក្សប្រជាជន *ហ៊ុន សែន* នោះក៏ដោយក៏សកម្មភាពរបស់ *សុក ផេង* ប្រើប្រាស់ដោយ *ហ៊ុន សែន* មិនបានសម្រេចបំណងនៅក្នុងខេត្តកំពង់ធំនោះទេ។

យ៉ាងណាៗនោះច្បាស់បំផុតគឺ គោលនយោបាយ និងសកម្មភាពគណបក្សប្រជាជនមានមូលដ្ឋានធំលើការភូតភរបោកប្រាស់ប្រជារាស្ត្រដើម្បីប្រាថ្នាចង់បានសន្លឹកឆ្នោតឱ្យគណបក្សនេះបន្តកាន់អំណាចដឹកនាំប្រទេសទាំងបង្កើតបញ្ហាច្របូកច្របល់គ្រប់ទីកន្លែងដូចជាការឆក់ប្លន់យកទ្រព្យសម្បត្តិដីធ្លីផ្ទះសម្បែងរបស់ប្រជារាស្ត្រ ឡូតិ៍នេសាទរបស់ប្រជារាស្ត្រការកាប់បំផ្លាញធនធានព្រៃឈើ ក៏ដូចជាការលក់ដីរដ្ឋត្រង់កន្លែងសំខាន់ៗជាតំបន់សក្តានុពលសេដ្ឋកិច្ចទាំងក្នុងទីក្រុង តាមបណ្តោយផ្លូវជាតិ រហូតដល់ក្នុងសមុទ្រ៕

---

**តមកពីទំព័រ១ ៩**

មន្ត្រី*ហ៊ុន សែន* ហើយ, ដែលទ្រង់ បានទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដ៏អាក្រក់នៅថ្ងៃទី១២ សីហា ២០០៨ នៅពេលដែលលោក*ហ៊ុន សែន*មិនទាន់ស្នើទៅព្រះមហាក្សត្រ ឱ្យប្រទាន ការលើកលែងទោសផងនោះ ។

ព្រះអង្គ កំពុងតែត្រូវលោក *ហ៊ុន សែន* ស្នើឱ្យដកមន្ត្រីនេះមន្ត្រីនោះជាបន្តបន្ទាប់ ដូចជាថ្មីៗនេះ សម្តេចក្រុមព្រះ យល់ព្រមតាមលោក*ហ៊ុន សែន* ដកលោក*មុត ចន្ថា* អ្នកនាំពាក្យដ៏មានថ្វីមាត់ ពីគណបក្សជាដើម ។ ដូច្នេះនៅពេលអនាគតខាងមុខដ៏ឆាប់នេះ លោក*ហ៊ុន សែន* នឹងស្នើសម្តេចក្រុមព្រះឱ្យដកមន្ត្រីណា ដែលស្រឡាញ់ដង្ហែតាមព្រះអង្គ ជាបន្តទៀតជាថ្នូរនឹងពាក្យ ដែលមានតែបបូរមាត់ថា ស្នើទៅព្រះមហាក្សត្រ ប្រទានការលើកលែងទោសថ្វាយព្រះអង្គ ដើម្បីឱ្យព្រះអង្គយាងត្រឡប់ ចូលប្រទេសវិញបាន ។

ស្ថិតក្នុងភាពមិនច្បាស់លាស់នេះ ត្រូវបានគេមើលឃើញថាសម្តេចក្រុមព្រះ កំពុងតែយាងចូលព្រះអន្ទាក់ លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ហើយ ជាសំខាន់ គឺលោកនាយករដ្ឋមន្ត្រី *ហ៊ុន សែន* កំពុងតែបង្ខំអោយព្រះអង្គ មកដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិចវិញ និងទទួលយកលក្ខខណ្ឌទាំងអស់ របស់ថ្នាក់ដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិច ។ ការដាក់សម្ពាធ អោយវិលមកដឹកនាំហ៊្វុនស៊ិនប៉ិចវិញនេះ វាដូចជាលោក*ហ៊ុន សែន* បង្ខំឱ្យសម្តេចក្រុមព្រះ សោយព្រះកំហាកខ្លួនឯងវិញដែរ ពីព្រោះព្រះអង្គ បានប្រកាសជាច្រើនដងហើយថា សុខចិត្តរស់បែបជានិរទេសគឺមិនព្រមទៅដឹកនាំហ៊្វុនស៊ិនប៉ិច និងយាងទៅជួយដង្ហែសពហ៊្វុនស៊ិនប៉ិចវិញ ជាដាច់ខាត ។

ប៉ុន្តែ ដើម្បីបានចូលប្រទេសវិញ ពូថាសម្តេចក្រុមព្រះគ្មានច្រកណា ដែលអាចយាងចូលប្រទេសវិញ តាមច្រកមកធ្វើជាប្រធានហ៊្វុនស៊ិនប៉ិចតាមការបញ្ជា របស់លោក*ហ៊ុន សែន* នោះទេ, ដែលព័ត៌មាននេះបានធ្វើអោយអ្នកចាស់ទុំ អតីតអ្នកតស៊ូ និងមន្ត្រីល្អៗរបស់គណបក្សហ៊្វុនស៊ិនប៉ិចមួយចំនួន ព្រមានដើរចេញ ពីគណបក្សហ៊្វុនស៊ិនប៉ិច បើសិនជាសម្តេចក្រុមព្រះ មិនទទួលយកលក្ខខណ្ឌពីថ្នាក់ដឹកនាំហ៊្វុនស៊ិនប៉ិចទេ ។ លក្ខខណ្ឌរបស់ថ្នាក់ដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិចនោះ គឺហាមមិនឱ្យសម្តេចក្រុមព្រះ ធ្វើការអត្តនោម័ត និងមិនឱ្យអ្នកម្នាង*អ៊ុក ផល្លា* លូកដៃចូលទៅក្នុងកិច្ចការផ្ទៃក្នុង របស់គណបក្សដូចមុនជាដាច់ខាត ។

ប្រភព ដែលធ្លាយចេញពីព្រះបរមរាជវាំង បានអោយដឹងថា កាលពីថ្ងៃទី១១ សីហា ២០០៨ មានព័ត៌មានថាលោក *ហ៊ុន សែន* យល់ព្រមធ្វើលិខិតស្នើព្រះមហាក្សត្រ ព្រះបរមនាថ*នរោត្តម សីហមុនី* ប្រទានការលើកលែងទោស ថ្វាយព្រះអង្គម្ចាស់*រណឫទ្ធិ* ហើយ តែស្ងប់ស្ងាត់ទៅវិញ ដោយសារលោក*ហ៊ុន សែន* ខឹង នឹងព្រះអង្គស្នើតំណែងច្រើនពេក នៅក្នុងរដ្ឋាភិបាលចម្រុះ ។ ប្រភពបានឱ្យដឹងទៀតថាឥឡូវលោក *ហ៊ុន សែន* កំពុងតែខឹង ហើយទំនងជា នៅក្រោយការបង្កើតរដ្ឋសភា និងរដ្ឋាភិបាលកញ្ចប់រួចរាល់ហើយ ទើបគិតពីរឿងលើកលែងទោស ថ្វាយសម្តេច

**តនៅទំព័រ៣ ៩**

---

**តមកពីទំព័រ១ ស**

*ទាហានរត់ចោលជួរ*"។

លិខិតអនាមិកមួយច្បាប់មានពីរទំព័រដែលបានផ្ញើមក "*ខ្មែរម្ចាស់ស្រុក*"កាលពីម្សិលមិញនេះបានរៀបរាប់យ៉ាងវែងអន្លាយថា ប្រការដែលលោក *ម៉ឹង សំផន* មានឋានន្តរស័ក្តិជានាយឧត្តមសេនីយ៍ផ្កាយមាស៤ និងជារដ្ឋលេខាធិការក្រសួងការពារជាតិ គឺជារឿងអាស្រូវអាសោចិ៍របស់ក្រសួងការពារជាតិតែម្តង។

លិខិតបានបន្តទៀតថា "*ហើយក៏ជាការចំអកយ៉ាងងងើលទៅដល់ព្រលឹងរបស់អតីតយុទ្ធជនវីរជនដែលបានបូជាជីវិតក្នុងបុព្វហេតុការពារជាតិ មាតុភូមិ និងជាលទ្ធផលគឺទុកឱ្យក្រុមគ្រួសាររស់នៅកំព្រីកំព្រាក្រីក្រទុរគតដែលគ្រួសាររបស់អតីតយុទ្ធជនទាំងនេះខ្លះត្រូវគេបណ្តេញចេញពីលំនៅស្ថានដ៏រខេករខាកដើម្បីគេវាតយកដី និងអភិវឌ្ឍន៍សំណង់ថ្មីជាដើម*"។

លិខិតដដែលនេះបានគូសបញ្ជាក់ច្បាស់ៗថានៅទស្សវត្សរ៍ដើមឆ្នាំ៨០ លោក *ម៉ឹង សំផន* ជានាយពិធីការរបស់កងពលលេខ៤ ក្រោមបញ្ជាការរបស់លោក *ជា ម៉ន* ដែលឈរជើងនៅស្រុកចំការលើ ខេត្តកំពង់ចាម។ នៅពេលនោះដោយសារមានសង្គ្រាមក្តៅគគុក និងមានយុទ្ធមិត្តស្លាប់ និងពិការជាបន្តបន្ទាប់ ធ្វើឱ្យលោក *ម៉ឹង សំផន* រត់ចោលជួរមិនដឹងជាទៅទីណាពិតប្រាកដនោះទេ។

ប៉ុន្តែរយៈពេលក្រោយមកទៀត ដោយសម្លឹងឃើញលាភសក្ការៈដ៏ក្រាស់ក្រែលនៅស្នងការហិរញ្ញវត្ថុ (បច្ចុប្បន្នហៅថានាយកដ្ឋានហិរញ្ញវត្ថុ) ដែលដឹកនាំដោយលោក *ទេព លឹមផន* នោះ ទើបលោក *ម៉ឹង សំផន* បានទៅពឹងពាក់លោក *ទេព លឹមផន* ដែលធ្លាប់ស្គាល់គ្នាដើម្បីបានចូលធ្វើការនៅទីនោះ។

ដោយដឹងពីប្រវត្តិលោក *ម៉ឹង សំផន* ថាជាទាហានធ្លាប់រត់ចោលជួរដែលរបបកុម្មុយនីស្តបានចាត់ទុកថា ជាប្រភេទមនុស្សដែលមានប្រវត្តិរូបមិនល្អ នោះគឺលោក *ទេព លឹមផន* បានជួយណែនាំ និងឱ្យទៅទំនាក់ទំនងជាមួយលោក *បុត្រ* ដែលជាជំនួយការរបស់សមមិត្តនារី *ម៉ែន សំអន* ដែលខណៈនោះសមមិត្តនារី *ម៉ែន សំអន* ជាប្រធានស្នងការចាត់តាំង (បច្ចុប្បន្ននាយកដ្ឋានបុគ្គលិក) ដើម្បីឈូសសំអាតប្រវត្តិរូបលោក*ម៉ឹង សំផន*ឱ្យស្អាតឡើងវិញ។

លិខិតនោះបានសរសេរថា "*លោក ម៉ឹង សំផន បានជូនជាសគុណដល់លោក បុត្រ នូវទូរទស្សន៍ពណ៌ ស-ខ្មៅ មួយគ្រឿង*"។ លុះដល់បានទៅធ្វើការនៅស្នងការហិរញ្ញវត្ថុដូចសេចក្តីប្រាថ្នាហើយក៏ស្រាប់តែលោក *ម៉ឹង សំផន* ដ៏មហិមាបានប៉ែងលោក *ទេព លឹមផន* ឱ្យខ្ទាតចេញពីតួនាទីរបស់ខ្លួនដែលមិនខុសអ្វីពីពាក្យថា"*ដល់ត្រើយ សើយគូថ*" នោះទេ។

លិខិតបានបន្តថាទង្វើរបស់លោក *ម៉ឹង សំផន* បែបនេះហើយដែលធ្វើឱ្យលោក *ទេព លឹមផន*កើតរោគសតិអារម្មណ៍អាក់អន់ស្រពន់ចិត្តជាមួយថ្នាក់លើដែលមានភ្នែកស្អុយ រហូតរត់ទៅចុះចូលជាមួយបក្សនយោបាយផ្សេងទៀត ក្នុងអំឡុងពេលបោះឆ្នោតដែលរៀបចំឡើងដោយអ៊ុនតាក់។

លិខិតអនាមិកនេះបានអះអាងថា "*លោក ម៉ឹង សំផនគ្មានចំណេះដឹង និងសញ្ញាប័ត្រអ្វីជាដុំកំភួននោះទេ ក្រៅតែពីការបំពាក់បំប៉នជំនាញដោយជំនាញការវៀតណាម និងពូកែរកខ្មែរទុយោតែប៉ុណ្ណោះ ហើយក៏ពុំដែលឆ្លៀតរៀនបំពេញចំណេះដឹងបន្ថែមដូចមន្ត្រីរាជការដែលកំពុងរៀនយ៉ាងសស្រាក់សស្រាំដើម្បីទប់តំណែងសព្វថ្ងៃនេះដែរ*"។

លិខិតបានលាតត្រដាងបន្តទៀតថា "*អចលនទ្រព្យមួយចំនួនរបស់ក្រសួងការពារជាតិបានក្លាយទៅជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់លោក ម៉ឹង សំផនរួចទៅហើយ ដោយគាត់នេះតែងតែប្រើប្រាស់ឥទ្ធិពលថ្នាក់ដឹកនាំប្រទេស*"។

ជាក់ស្តែងឃ្លាំង K7 ក្បែរផ្លូវរទេះភ្លើងម៉ុំពោធិ៍ចិនតុង ជារបស់ក្រសួងការពារជាតិ ដែលបានជួលឱ្យរោងចក្រកាត់ដេរអស់ជាច្រើនអាណត្តិរដ្ឋាភិបាលមកហើយនោះ គឺពុំដែលមានថវិកាមួយចម្រៀកពុះជាបួនណាធ្លាក់មកដល់ហិបថវិកាក្រសួងដើម្បីបន្ថយបន្ទុកចំណាយរបស់ក្រសួងឡើយ។

បានសេចក្តីថាចំណូលប្រាក់ឈ្នួលទាំងនោះត្រូវធ្លាក់ចូលទៅក្នុងហោប៉ៅលោក *ម៉ឹង សំផន* ទាំងដុលតែម្តង។ ដោយសារតែហេតុផលនេះហើយ ទើបមានមន្ត្រីនៅក្រសួងការពារជាតិខ្លះព្រួយបារម្ភថា អាចនឹងមានថ្ងៃណាមួយលោក *ម៉ឹង សំផន* នឹងកាត់យកឃ្លាំងមួយនេះដាក់ជាកម្មសិទ្ធិផ្តាច់មុខរបស់គាត់ទៀតជាមិនខាន ព្រោះដីភូមិគ្រឹះជាប់ក្រសួងការពារជាតិដែលពីមុននេះស្ថិតក្នុងបរិវេណក្រសួងការពារជាតិសោះ តែបច្ចុប្បន្នក្លាយជាគេហដ្ឋានដ៏ស្កឹមស្កៃរបស់កូនស្រីគាត់រួចទៅហើយ។ សួរថា តើអ្នកណាអាចធ្វើដូចលោក *ម៉ឹង សំផន* ទេ ?

នៅមានដីរបស់វិស្វកម្មនៅម៉ុំព្រែកព្នៅ តាមបណ្តោយផ្លូវជាតិលេខ៥ទៀត ដែលនៅជាប់ដីរបស់លោក *ម៉ឹង សំផន* ក៏ត្រូវគាត់ច្រឹបយកមួយផ្នែកដែរ បើទោះជាមន្ត្រីយោធានៅទីនោះព្រម ឬមិនព្រមក៏ដោយ ក៏ត្រូវតែបិទមាត់ដូចគេចុក។ ហើយនៅមានច្រើនកន្លែងទៀតដែលលោក *ម៉ឹង សំផន* ម្នាក់នេះបានច្រឹបយកពីអចលនទ្រព្យរបស់ក្រសួង ដោយគេពុំទាន់បានដឹងឱ្យប្រាកដនៅឡើយ។

លិខិតដែលបានផ្ញើមក*ខ្មែរម្ចាស់ស្រុក* កាលពីម្សិលមិញនេះបានរៀបរាប់ថា "*លោក ម៉ឹង សំផន មិននិយមការស៊ីផឹកប៉ុន្មានទេ តែបើមានពិធីហើយ ត្រូវគេបញ្ចោរនោះ គឺគាត់នឹងបញ្ចេញឱ្យដឹងខ្លះៗដែរ*"។

កាលនៅជាឧត្តមសេនីយ៍ឯករាល់ពេលមានពិធីផ្សេងៗ ឱ្យតែក្រុមឡេមឡឺមដែលនៅក្បែរតែងតែហៅលោក *ម៉ឹង សំផន* ថាជា "*ឯកឧត្តមនាយឧត្តមសេនីយ៍ផ្កាយមាស៤*" ធ្វើឱ្យលោកសប្បាយភ្លេចខ្លួន រហូតភ្លាត់មាត់អួតប្រាប់គេឯងថា "*ប្រាក់ដុល្លាររបស់គាត់អាចតម្រៀបតាមផ្លូវពីភ្នំពេញដល់ក្រុងសៀមរាបបានដោយមិនឱ្យមានចន្លោះឡើយ*"។

លិខិតដដែលនេះបានបញ្ជាក់ច្បាស់ថា មានដីជាច្រើនហិកតាទៀតដែលគេមិនទាន់ដឹង។ តែអ្វីដែលគេដឹងនោះ គឺលោក *ម៉ឹង សំផន* មានដីជាង៣០០ហិកតានៅម៉ុំត្រែងត្រយឹងក្បែរតំបន់អភិវឌ្ឍន៍កងពលតូចលេខ៧០ ដោយហៀរពីតំបន់ក្នុងនោះមកជាប់នឹងបណ្តោយផ្លូវជាតិលេខ៤ និងល្បីថា ដីនៅតំបន់នេះមានតម្លៃក្នុងមួយម៉ែត្រការ៉េជិតសាមសិបដុល្លារអាមេរិកឯណោះ។

លោក *ម៉ឹង សំផន* មិនត្រឹមតែមានទ្រព្យសម្បត្តិមហាសាលនៅក្នុងស្រុកខ្មែរប៉ុណ្ណោះទេ ពោលគឺគាត់មានភូមិគ្រឹះលំហែកាយសម្រាប់ក្រុមគ្រួសារគាត់នៅតំបន់សាព្រីងវេល ក្រុងមែលប៊ិនប្រទេសអូស្ត្រាលីជាប់មាត់សមុទ្រដែលមានតម្លៃខ្ទង់លានដុល្លារអាមេរិក ដែលមានបងប្អូនខ្មែររស់នៅទីនោះបានដឹងរឿងនេះច្បាស់ណាស់។

មិនអាចសុំការបកស្រាយណាមួយពីលោកនាយឧត្តមសេនីយ៍ *ម៉ឹង សំផន* រដ្ឋលេខាធិការក្រសួងការពារជាតិបាននៅឡើយទេ ទាក់ទិននឹងខ្លឹមសារនៃលិខិតអនាមិកចំនួន២ទំព័រនេះ។ ប៉ុន្តែសម្រាប់ "*ខ្មែរម្ចាស់ស្រុក*"វិញនឹងធ្វើការស្រាវជ្រាវព័ត៌មាននេះឱ្យកាន់តែពិស្តារថែមទៀត ដើម្បីចុះផ្សាយនៅលេខក្រោយជាបន្តបន្ទាប់ទៀត៕

**តមកពីទំព័រ១ គ**

ស្រាយបញ្ហាជាមួយនឹងចោរសៀមឈ្លានពានកម្ពុជា នៅតាមបណ្តោយព្រំដែនខាងលិចពិសេសនៅតំបន់ក្បែរប្រាសាទព្រះវិហារនិងតំបន់ផ្សេងៗទៀតដូចជាប្រាសាទ តាមាន់ធំជាដើម ។

មន្ត្រីគណបក្សសម រង្ស៊ីបាន អោយដឹងថា ការស្នើសម្តេចឪអោយធ្វើជាអ្នកដឹកនាំ ក្នុងការដោះស្រាយបញ្ហា ជាមួយនឹងចោរសៀម ដែលកំពុងឈ្លានពានបូរណភាពទឹកដីនេះដោយសារព្រះអង្គជាសហប្រធានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១ ដែលមានប្រទេសចំនួន១៨ ជាហត្ថលេខីធ្វើជាសាក្សី ។

លោក*សុនឆ័យ*អ្នកនាំពាក្យគណបក្សសម រង្ស៊ី បានអោយដឹងថា គណបក្សសម រង្ស៊ី ពិតជាបានសរសេរលិខិតថ្វាយទៅសម្តេចឪ ព្រះ*នរោត្តម សីហនុ* មែនប៉ុន្តែលោកមិនបានអោយដឹងអំពីខ្លឹមសារ នៃលិខិតនោះទេ ។ លោក*សុន ឆ័យ* បានឱ្យដឹងថា លោកមិនទាន់ធ្វើអត្ថាធិប្បាយ អំពីខ្លឹមសារនៃលិខិតនេះទេ ដោយរង់ចាំឆ្លងការសំ

---

**តមកពីទំព័រ២ ៩**

ក្រុមព្រះ ។

សេចក្តីរាយការណ៍ បានឱ្យដឹងទៀតថា ប៉ុន្មានថ្ងៃនេះ ប្រមុខរដ្ឋាភិបាល បានស្នើទៅព្រះអង្គម្ចាស់*រណឫទ្ធិ* ៣ចំណុច គឺឱ្យធ្វើលិខិត ទទួលស្គាល់ លទ្ធផលបោះឆ្នោត, ស្នើអោយដកលោក*មុត ចន្ថា* ពីអ្នកនាំពាក្យគណបក្សនរោត្តម រណឫទ្ធិនិងស្នើអោយផ្ទេរតំណែង តំណាងរាស្ត្ររបស់ព្រះអង្គ អោយទៅលោក*យូ ហុកគ្រី* ។

អ្នកចាស់ទុំ គណបក្សហ៊ុនសិុនប៉ិច បាននិយាយថាលោក*យូ ហុកគ្រី* នៅតែជាមនុស្សរបស់លោក*ហ៊ុន សែន* ក្នុងការបំផ្លាញ គណបក្សហ៊ុនសិុនប៉ិចឱ្យចុះខ្សោយដូចសព្វថ្ងៃនេះ ។ ដូច្នេះគេសង្ស័យថា លោក*ហ៊ុន សែន* ដាក់លក្ខខណ្ឌចុងក្រោយឱ្យសម្តេចក្រុមព្រះ ជាថ្នូរនឹងការលើកលែងទោសនោះ គឺអោយព្រះអង្គ ផ្ទេរគណបក្សនរោត្តម រណឫទ្ធិ ឱ្យលោក *យូ ហុកគ្រី*និងមិនអោយធ្វើនយោបាយ ទើបលោក*ហ៊ុន សែន* សរសេរលិខិត ស្នើព្រះមហាក្សត្រ ប្រទានការលើកលែងទោសថ្វាយព្រះអង្គ ។

អ្នកស្មោះត្រង់ នឹងសម្តេចក្រុមព្រះម្នាក់ បាននិយាយថាអនាគតដ៏ឆាប់ខាងមុខនេះ ប្រមុខរដ្ឋាភិបាល*ហ៊ុន សែន* ធ្វើឱ្យព្រះអង្គភ្ញាក់ខ្លួនម្តងទៀតពីព្រោះ ព្រះអង្គទទួលយកនូវលក្ខខណ្ឌលោក*ហ៊ុន សែន*ទាំងអស់ ដើម្បីបានយាងត្រឡប់ចូលប្រទេសវិញដែលការយាងចូលនេះ បានត្រឹមតែរស់នៅជាមួយអ្នកម្នាង*អ៊ុកផល្លា*តែគ្មានអំណាចអ្វីដូចមុនទេ ៕

---

**តមកពីទំព័រ១ ឃ**

និងបណ្តាប្រទេស ដែលជាហត្ថលេខី នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅថ្ងៃទី២៣ តុលា ១៩៩១ ។

មន្ត្រីខុទ្ទកាល័យ គណបក្សសម រង្ស៊ី បានអោយដឹងថា បើតាមគំរោង លោក*សម រង្ស៊ី* នឹងចេញដំណើរ ទៅទីក្រុងប៉ារីស ប្រទេសបារាំង នៅម៉ោង ៧:៤៥ នាទីព្រឹកនេះតាមជើងយន្តហោះរបស់ក្រុមហ៊ុនTG ។ ប៉ុន្តែបានលើកពេល ទៅពេលល្ងាចវិញ ដោយសារនៅម៉ោង ១០: ០០នាទីព្រឹក លោកចូលរួម នៅក្នុងសន្និសីទកាសែតជាមួយគណបក្សសិទ្ធិមនុស្សដែលជាដៃគូដ៏សំខាន់ក្នុងការតវ៉ាប្រឆាំងនឹងលទ្ធផល នៃការលួចបន្លំសន្លឹកឆ្នោត កាលពីថ្ងៃទី ២៧ កក្កដា ២០០៨ ។

មន្ត្រីខុទ្ទកាល័យ របស់គណបក្សសម រង្ស៊ី បានអោយដឹងទៀតថា លោក*កឹម សុខា* ក៏ទំនងជា នាំយកភស្តុតាង និងឯកសារ ទៅប្តឹងអង្គការសហប្រជាជាតិ ជាមួយលោក*សម រង្ស៊ី* ដែរនៅល្ងាចថ្ងៃនេះដែរ ។

គណបក្សសម រង្ស៊ី នៅសល់អាសនៈចំនួន២៦ ពីការលួចបន្លំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) និងគណបក្សសិទ្ធិមនុស្ស នៅសល់តែ៣ប៉ុណ្ណោះ, ហើយអ្នកតំណាងរាស្ត្រសរុប របស់គណបក្សទាំងពីរ ចំនួន២៩រូប បានប្តេជ្ញាចិត្តថា មិនចូលរួមប្រជុំសភាដំបូង នៅថ្ងៃទី២៤ ខែកញ្ញា ២០០៨ជាដាច់ខាត បើទោះបីជាលោក*ហ៊ុន សែន* និងមន្ត្រីគណបក្សប្រជាជន បានព្រមានថានឹងយកអាសនៈទាំង២៩នេះក៏ដោយ ។

ប៉ុន្តែអ្នកតំណាងរាស្ត្រ នៃគណបក្សទាំងពីរនឹងចូលស្បថនៅក្នុងព្រះបរមរាជវាំង ឬនៅកន្លែងណាមួយផ្សេង នៅដាច់ដោយឡែក នៅល្ងាចនៃថ្ងៃលោក*ហ៊ុន សែន* បង្កើតរដ្ឋសភា និងរដ្ឋាភិបាលកញ្ចប់ ។

អ្នកជំនាញច្បាប់ បានអោយដឹងថា លោក*ហ៊ុន សែន* និងថ្នាក់ដឹកនាំ គណបក្សប្រជាជនព្រមានថា នឹងយកអាសនៈពីគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ដែលធ្វើពហិការមិនចូលប្រជុំ នៅថ្ងៃដំបូងទៅចែកគ្នានោះ គឺជាព្រមានតែប៉ុណ្ណោះ ព្រោះមិនអាចទៅរួចទេ ។ ម៉្យាងលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* បញ្ជាអោយរៀបចំ បោះឆ្នោតដោយលើកដៃ បង្កើតរដ្ឋសភា និងរដ្ឋាភិបាលកញ្ចប់នេះ វាខុសនឹងរដ្ឋធម្មនុញ្ញ ត្រង់មានត្រា៧៦ នៃច្បាប់កំពូល របស់ជាតិណាស់ទៅហើយ ។ ដូច្នេះការព្រមានថា នឹងយកអាសនៈរបស់គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ទៅចែកគ្នានេះវាមិនអាចធ្វើទៅបានទេ ហើយសមាជិកសភា គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ទាំង២៩រូបនោះ ក៏មិនចាញ់សំឡុតលោក*ហ៊ុន សែន* និងមន្ត្រីគណបក្សប្រជាជនដែរ ។

អ្នកជំនាញច្បាប់ ផ្នែកច្បាប់រដ្ឋធម្មនុញ្ញ បានអោយដឹងថា បើសិនជា ការប្រជុំសភា នៅថ្ងៃដំបូង អវត្តមានរបស់អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី មិនគ្រប់១២០រូប តាមមាត្រា ៧៦នោះ គឺជាសភាខ្មែរក្លាយជាសភាខុសច្បាប់ សភាមិនពេញមុខ, ហើយសហគន៍អន្តរជាតិនិងអង្គការសហប្រជាជាតិ គេនឹងមិនទទួលស្គាល់ឡើយ ។ ដូច្នេះរដ្ឋាភិបាល ដែលបង្កើតចេញពីសភាដែលមិនពេញមុខនេះ ក៏មិនស្របច្បាប់ដែរ ៕

**ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍**

**ផ្សព្វផ្សាយពាណិជ្ជកម្ម**

**លើទំព័រសារព័ត៌មានខ្មែរម្ចាស់ស្រុក**

**សូមទាក់ទងមកកាន់**

**ទូរស័ព្ទ : 012 850 690, 015 645 170**

**ទូរសារ : 023 987 411**

E-mail : kmsnews@gmail.com



រេចពីលោក*សម រង្ស៊ី* និងថ្នាក់ដឹកនាំគណបក្សសម រង្ស៊ី រួចរាល់សិន ។

មុនមួយថ្ងៃ នៃការសរសេរលិខិតស្នើសម្តេចឪ អោយដោះស្រាយបញ្ហា បូរណភាពទឹកដីនេះ ថ្នាក់ដឹកនាំគណបក្សសម រង្ស៊ីបានពិភាក្សាគ្នាក្នុងកិច្ចប្រជុំរបស់សមាជិកគណៈកម្មាធិការនាយក នៅទីស្នាក់ការកណ្តាលក្រុងភ្នំពេញ កាលពីថ្ងៃទី០២ កញ្ញា មិនសំរាប់តែជាមួយនឹងប្រទេសសៀមនោះទេ គឺមានទាំងព្រំដែនខាងកើតដែលមានសេចក្តីរាយការណ៍ថា ក៏មានការបាត់បង់ដែរនោះ ពិសេសព្រំដែនជាប់ប្រទេសយួន ។

មន្ត្រីគណបក្សសម រង្ស៊ីបាននិយាយថា សម្តេចឪបានឈ្នះក្តីជាមួយសៀម នៅទីក្រុងឡាអេកាលពីថ្ងៃទី១៥ មិថុនា ឆ្នាំ ១៩៦២ ដែលស្នាព្រះហស្តនេះត្រូវបានថ្នាក់ដឹកនាំ គណបក្សប្រជាជន ធ្វើអាជីវកម្មនយោបាយ មុនការបោះឆ្នោតក្រោមរូបភាព ដាក់បញ្ចូលប្រាសាទព្រះវិហារ ជាបេតិកភ័ណ្ឌពិភពលោក ដែលបណ្តាលឱ្យមានបញ្ហាយ៉ាងស្មុគស្មាញរហូតសព្វថ្ងៃនេះ ។ ភាពព្រងើយកន្តើយ និងអសមត្ថភាព របស់លោក*ហ៊ុន សែន* នៃគណបក្សប្រជាជននេះ បានធ្វើឱ្យចោរសៀមបានចិត្ត ហើយមើលងាយខ្មែរបន្តឈ្លានពាន បូរណភាពទឹកដីខ្មែរជាបន្តបន្ទាប់ នៅតាមព្រំដែន ។

ក្រុមអ្នកច្បាប់ បាននិយាយថា សំណើរបស់គណបក្សសម រង្ស៊ី ពិតជាត្រឹមត្រូវ ហើយក៏ជាការរំលឹក នូវស្នាព្រះហស្តរបស់សម្តេចឪ ក្នុងការឈ្នះក្តីសៀម ករណីប្រាសាទដ៏វិយចំណាស់របស់ខ្មែរមួយនេះ ។

ក្រុមអ្នកច្បាប់ ក៏បានលាតលាតត្រដាងនូវសម្តីលោក*ហ៊ុន សែន* រិះគន់សហរដ្ឋអាមេរិក, អង្គការសហប្រជាជាតិ និងតំណាងពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិនៅកម្ពុជា ដែលធ្វើអោយគាត់មិនហ៊ានទៅពឹងអង្គការ សហប្រជាជាតិ ឱ្យជួយធ្វើអន្តរាគមន៍រឿងសៀមឈ្លានពាន បូរណភាពទឹកដីខ្មែរ ។ ក្រុមអ្នកច្បាប់ខ្មែរ បានស្តីបន្ទោសលោក*ហ៊ុន សែន*ដែលប្រើលោក*សុខ អាន* ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោក*វ៉ា គឹមហុង* ប្រធានគណៈកម្មការ ព្រំដែនកម្ពុជា គឺជាមនុស្សគ្មានសមត្ថភាព ក្នុងការធ្វើការជាមួយនឹងសៀម ។

ក្រុមអ្នកច្បាប់ បានបន្តថា លោក*ហ៊ុន សែន* ជាមេដឹកនាំគ្មានសមត្ថភាព រៀនចេះដឹងទាប បណ្តោយឱ្យលោក*សុខ អាន* និងលោក*វ៉ា គឹមហុង* ធ្វើការងារព្រំដែន ជាមួយនឹងប្រទេសជិតខាងដូចសព្វថ្ងៃនេះ វាធ្វើឱ្យប្រទេសជាតិខាតបង់ ជាពិសេស ភាពអសមត្ថភាពនេះ ក៏ជាឱកាស អោយសៀមអាចតវ៉ាផ្លូវច្បាប់ នៅអង្គការសហប្រជាជាតិ នៅពេលអនាគតទៀតផង ដូចជាកម្ពុជា ដាក់ប្រាសាទព្រះវិហារ របស់ខ្លួនឯង ក៏ចាំបាច់ទៅសុំយោបល់ពីសៀមដែរនោះ ។ ក្រុមអ្នកច្បាប់ខ្មែរ ដែលមានចំណេះដឹងពិតប្រាកដ និងមិនលក់ឧត្តមគតិឱ្យលោក*ហ៊ុន សែន* បានឱ្យដឹងទៀតថា កម្ពុជាមិនខ្វះអ្នកចេះដឹងទេដែលមានសមត្ថភាពដែលអាចធ្វើការ ជាមួយចោរសៀមបាន តែលោក*ហ៊ុន សែន* មិនឱ្យគេធ្វើការងារនេះ និងមិនសុំយោបល់គេ ។ ដូច្នេះការចេះដឹងទាប និងស្តាប់តាមតែបណ្ឌិតសេះហោះ អត់ស្គាល់កាំជណ្តើរសាលានេះហើយ ទើបធ្វើឱ្យសៀម មើលងាយខ្មែររំលោភចូលដីខ្មែរ,ឯលោក*ហ៊ុន សែន* បាននិយាយត្រឹមតែថាអត់ធ្មត់គួរឱ្យអស់សំណើច ។

ក្រុមអ្នកច្បាប់ បានធ្វើការស្តីបន្ទោស រដ្ឋាភិបាលលោក*ហ៊ុន សែន* យកប្រាសាទព្រះវិហារ ធ្វើជាផលប្រយោជន៍រួមជាមួយចោរ ឈ្លានពានសៀម លើវិស័យទេសចរ ដែលនេះវាដូចជាក្បត់ នឹងព្រលឹងបុព្វបុរសខ្មែរយើង ដែលបានពន្យល់ទុកកេរមតិក ដល់កូនចៅមានតម្លៃមិនអាចកាត់ថ្លៃបាននេះ ។ ក្រុមអ្នកច្បាប់បានបន្តថាពិភពលោកគេដឹងថា តុលាការក្រុងឡាអេ បានកាត់ក្តីឱ្យខ្មែរយើងឈ្នះសៀម ជាង៤០ឆ្នាំហើយ ចាំបាច់អីទៅសុំយោបល់ ពីពួកចោរឈ្លានពានសៀមទៀត ពីរឿងចុះឈ្មោះ ប្រាសាទព្រះវិហាររបស់ខ្មែរ ជាបេតិកភ័ណ្ឌពិភពលោកនេះ បើសិនជាចោរសៀមចង់តវ៉ាអីនោះគួរតែធ្វើឡើង ១០ឆ្នាំបន្ទាប់ការកាត់ក្តី តែឥឡូវជាង៤០ឆ្នាំហើយ ពួកចោរសៀម មិនអាចចិញ្ចឹមនូវមហិច្ឆតាលេបត្របាក់ប្រាសាទខ្មែរនេះបានទេ ។

អ្នកច្បាប់ និងអ្នកស្នេហាជាតិខ្មែរជាច្រើននាក់ បានឱ្យដឹងថា ភាពទន់ជ្រាយ និងគ្មានសមត្ថភាពរបស់រដ្ឋាភិបាលខ្មែរក្រោមការដឹកនាំ របស់លោក*ហ៊ុន សែន* នេះ វាបានធ្វើឱ្យប្រជាពលរដ្ឋខ្មែរ សង្ស័យថា បើសិនជាចោរសៀម ប្រើកងទ័ពលុកលុយកម្ពុជា នាពេលក្រោយទៀត ហើយកម្ពុជានៅតែមានវិធានការ ដោះស្រាយជាមួយគេ ដោយសម្បទានឱ្យទៅសៀមទៀតឬយ៉ងណា ពីព្រោះចោរសៀមចង់បានប្រេងកាត ដែលជាសម្បត្តិដ៏មហាសាលរបស់ខ្មែរនៅបាតសមុទ្រសព្វថ្ងៃនេះ ។

ដូច្នេះហើយ ទើបគណបក្សសម រង្ស៊ី មានជំនឿទៅលើតែសម្តេចឪ ព្រះ*នរោត្តម សីហនុ* មួយគត់ក្នុងការដោះស្រាយនូវបញ្ហាជាមួយចោរសៀម ដ៏ក្តៅគគុកនៅតាមព្រំដែន និងថាព្រះអង្គជាសហប្រធានកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស ប្រទេសបារាំងកាលពីថ្ងៃទី២៣ តុលា ១៩៩១ផងដែរ ៕

---

**តមកពីទំព័រ៤ ម**

ម្តង ព្រោះក្រុមហ៊ុន និងសាលាក្រុងភ្នំពេញបានព្យាយាម"*ទក់ហាងឆេង* " តាំងពីយូរណាស់មកហើយ ។

មុនដំបូងសាលាក្រុងភ្នំពេញនិងក្រុមហ៊ុនគ្រោងជម្លៀសប្រជាពលរដ្ឋនៅតំបន់បឹងកក់ដូចអ្នកភូមិសំបុកចាបដែរតែពេលនោះអ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ីដែលរួមមានលោក *សុន ឆ័យ* និងលោក *ហូរ វ៉ាន់* ចេញមុខជួយអន្តរាគមន៍ខ្លាំងក៏ស្ងាត់ទៅវិញ ។

ក្រោយមកទើបលេចចេញនូវគម្រោងការដោះដូរជាលុយកាក់និងផ្ទះ១ល្វែងដែលគម្រោងនេះមានប្រជាពលរដ្ឋខ្លះទទួលយកបានឯប្រជាពលរដ្ឋខ្លះទៀតមិនអាចទទួលយកបានដែលផ្តើមឱ្យមានការតវ៉ាសាជាថ្មីយ៉ាងដូច្នេះ ។

គេថាខាងសាលាក្រុងភ្នំពេញព្យាយាមចេញមុខចេញមាត់ខ្លាំងណាស់ក្នុងរឿងអភិវឌ្ឍន៍ចាក់ដីលុបបឹងកក់នេះ ។ ហើយប្រសិនបើលើកនេះសាលាក្រុងនៅតែចេញមុខជួសក្រុមហ៊ុនកំណត់តម្លៃឱ្យប្រជាពលរដ្ឋទៀតយើងជឿថា សាលាក្រុងនឹងមានបញ្ហាធំជាមិនខាន ។

ឥឡូវនេះប្រជាពលរដ្ឋបានសំណូមពរយ៉ាងហ្មឹងម៉ាត់ថា "*យើងចង់ឱ្យលោកចៅហ្វាយក្រុងភ្នំពេញ និងក្រុមហ៊ុនស៊ូកាគូអ៊ីនដោះស្រាយបញ្ហានេះឱ្យបានឆាប់ ព្រោះការបូមខ្សាច់ដែលកំពុងដំណើរការឥតឈប់ឈរនេះ ធ្វើឱ្យទឹកបឹងកក់ជន់លិចផ្ទះពួកយើងអស់ហើយ* " ។

ទាក់ទិននឹងព័ត៌មានខាងលើនេះ យើងមិនអាចទំនាក់ទំនងសុំការបំភ្លឺពីលោក *កែប ជុតិមា* ចៅហ្វាយក្រុងភ្នំពេញ និងឧកញ៉ា *ឡាវ ម៉េងឃីន* ស្វាមីយាយភូបានទេកាលពីម្សិលមិញ ។ ប៉ុន្តែក្រុមអ្នកតាមដានបានលើកឡើងថា ការបូមខ្សាច់លុបបឹងកក់ដើម្បីធ្វើការអភិវឌ្ឍន៍រយៈពេល៩៩ឆ្នាំនេះ នឹងធ្វើឱ្យប៉ះពាល់ដល់បរិស្ថានក្នុងទីក្រុងភ្នំពេញធ្ងន់ធ្ងរណាស់ ។

គួររំលឹកផងដែរថានៅពេលដែលប្រជាពលរដ្ឋនៅតំបន់បឹងកក់តវ៉ាចង់ជួបដោះស្រាយជាមួយក្រុមហ៊ុនដោយផ្ទាល់ដើម្បីបញ្ចប់បញ្ហា ស្រាប់តែអាជ្ញាធរប្រើល្បិចគំរាមតាមកាសែតក្នុងស្រុកមួយថា គេបានរកឃើញអ្នកញុះញង់ដែលនាំឱ្យមានការតវ៉ានេះហើយៗគេគ្រោងនឹងចាត់វិធានការតាមផ្លូវច្បាប់ថែមទៀតផង ។

នេះគឺជាវិធីបំបាក់ស្មារតីប្រជាពលរដ្ឋមិនឱ្យធ្វើការតវ៉ា ហើយដែលយើងសូមឱ្យអង្គការសិទ្ធិមនុស្សនានាជួយការពារប្រជាពលរដ្ឋយើងផង ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**

មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំគ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។

-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា

-មានទទួលទិញក្នុងតម្លៃសមរម្យ

-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម

ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ក្រុមហ៊ុនភាពយន្ត ជនបទ**

**មានទទួលបញ្ចាំង**

**ខ្សែភាពយន្តខ្នាតធំ**

**ក្នុងពិធីផ្សេងៗ**

**មានពន្លឺច្បាស់**

**ទំនាក់ទំនងតាមទូរស័ព្ទ**

**012 66 44 67**

**015 66 44 67**

ការិយាល័យនិពន្ធ

Tel : 012 969 832 , 012 850 690

Fax : 023 987 411

E-mail: kmsnews@gmail.com

www.kmsblog.wordpress.com

ផ្នែកផ្សាយពាណិជ្ជកម្ម

Tel: 012 850 690 , 017 360 678,

015 645 170

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០៤**
Tel: 012 850 690 / 017 360 678 , Fax: 023 987 411

**តមកពីទំព័រ១ យ**

*នៅថ្ងៃទី២ ខែកញ្ញា នេះទេ* "។

លោក *សម រង្ស៊ី* បានបន្តទៀតថា យើងបានទទួលភស្តុតាងកាន់តែច្រើនឡើងៗសាក្សីកាន់តែច្រើនឡើងៗ ដែលបញ្ជាក់ថា ការបោះឆ្នោតនេះជាការលួចបន្លំសន្លឹកឆ្នោតច្រើនណាស់ដែលខុសប្លែកពីការបោះឆ្នោតមុនៗ ព្រោះមានការលុបឈ្មោះប្រជាពលរដ្ឋជាច្រើនដែលលោកមានបំណងទៅបោះឆ្នោត តែបែរជាមិនបានបោះឆ្នោត ដោយត្រូវគេលុបឈ្មោះ, លួចឈ្មោះក្នុងគោលដៅរារាំងមិនឱ្យបានបោះឆ្នោត។ នេះគឺជាបញ្ហាទីមួយ។

មេដឹកនាំគណបក្សប្រឆាំងដ៏ល្បីឈ្មោះរូបនេះបានមានប្រសាសន៍បន្ថែមទៀតថា "*បញ្ហាទីពីរមានការចេញទម្រង់១០១៨ដោយខុសច្បាប់ ព្រោះទម្រង់១០១៨នោះជាឯកសារក្លែងក្លាយដោយគេបានផ្តល់ទៅឱ្យអ្នកដែលគ្មានសិទ្ធិបោះឆ្នោតដូចជាជនជាតិយួន, ក្មេងមិនទាន់គ្រប់អាយុ, អ្នកដែលអត់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅតាមឃុំ នៅតាមការិយាល័យបោះឆ្នោតនីមួយៗ, គេផ្តល់ឈ្មោះក្លែងក្លាយឱ្យអ្នកទាំងនោះទៅបោះឆ្នោតឱ្យគណបក្សប្រជាជន* "។

ដូច្នេះសម្លេងច្រើនណាស់ដែលគណបក្សប្រជាជនអះអាងថាគេទទួលបាននោះគឺមានចំនួនរាប់សែននាក់ ដែលយ៉ាងតិចណាស់ក៏មានចំនួន៥សែននាក់ដែរ ដែលបានមកពីសម្លេងដែលមិនមែនជាសម្លេងពិតប្រាកដគឺជាសម្លេងខ្មោច យកឈ្មោះខ្មោចទៅប្រើ។ ហើយម្យ៉ាងទៀតមានប្រជាពលរដ្ឋរាប់លាននាក់ដែលយ៉ាងតិចណាស់ក៏ជាង១លាននាក់ដែរ ត្រូវគេលុបឈ្មោះ, លួចឈ្មោះ រារាំងមិនឱ្យបានទៅបោះឆ្នោត។

ប្រការនេះហើយដែលធ្វើឱ្យសម្លេងគណបក្សប្រឆាំងចុះថយដោយសារតែអ្នកដែលចង់បោះឆ្នោតឱ្យគណបក្សប្រឆាំងមិនបានទៅបោះឆ្នោត។ ផ្ទុយទៅវិញអ្នកដែលអត់មានសិទ្ធិបោះឆ្នោតសោះ ត្រូវបានគណបក្សប្រជាជនសម្រួលដោយខុសច្បាប់ចេញទម្រង់១០១៨ក្លែងក្លាយឱ្យទៅបោះឆ្នោត។

លោក *សម រង្ស៊ី* បានសង្កត់ធ្ងន់ថា "*លទ្ធផលបោះឆ្នោតនេះវាក្រឡាប់ចាក់វាមិនឆ្លុះបញ្ចាំងទាល់តែសោះវាបំភ្លៃឆន្ទៈប្រជាពលរដ្ឋយើងទាំងស្រុង។ ហើយយើងប្រកាសម្តងទៀតនូវគោលជំហរគណបក្សសមរង្ស៊ីនិងគណបក្សសិទ្ធិមនុស្សដែលប្រឆាំងចំពោះទង្វើអាក្រក់របស់គណបក្សប្រជាជនតាមរយៈគ.ជ.ប, តាមរយៈក្រុមប្រឹក្សាធម្មនុញ្ញដែលបំរើតែគណបក្សប្រជាជននោះ* "។

លោកបានបន្តទៀតថា បន្ទាប់ពីនេះ គឺនៅមានដំណឹងមួយទៀត "*ដែលរូបខ្ញុំ សម រង្ស៊ី នឹងចេញដំណើរទៅតវ៉ាដល់សហគមន៍អន្តរជាតិនៅថ្ងៃពុធ នេះហើយ។ ខ្ញុំទៅទ្វីបអឺរ៉ុប ទ្វីបអាមេរិក, ទីក្រុងប៉ារីស, ទីក្រុងប្រ៊ុចសែល, ទីក្រុងញូវយ៉ក, ទីក្រុងវ៉ាស៊ីនតោន ដើម្បីទៅប្តឹងអន្តរជាតិពីការលួចបន្លំសន្លឹកឆ្នោត។ ហើយខ្ញុំមានភស្តុតាងច្រើនណាស់ ដូចខ្ញុំបាននិយាយអម្បាញមិញ ភស្តុតាងនោះខ្ញុំបានលាតត្រដាងតាមរយៈវិបសាយ ឬប្រព័ន្ធអ៊ីនធឺណេត យើងប្រើបច្ចេកវិជ្ជាទំនើបដើម្បីឱ្យពិភពលោកទាំងមូលឃើញនោះជា អ្នកណាចង់មើលក៏អាចមើលបានដែរ* "។

ភស្តុតាងនេះសឱ្យឃើញថាការបោះឆ្នោតនៅប្រទេសកម្ពុជាមិនត្រឹមត្រូវទេ ពីព្រោះយើងបានទទួលពញ្ញត្តិ ស្នាមមេដៃរបស់ប្រជាពលរដ្ឋរាប់ម៉ឺននាក់ដែលបានត្អូញត្អែរសម្តែងការមិនពេញចិត្តនូវទង្វើ គ.ជ.ប ដែលបានលុបឈ្មោះគេនោះ។

លោក *សម រង្ស៊ី* បានបន្តទៀតថា ប្រជាពលរដ្ឋទាំងនោះបានធ្វើញត្តិផ្តិតមេដៃមកពីទូទាំងប្រទេសចំនួនរាប់ម៉ឺននាក់ និងកំពុងតែកើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ។ ហើយមិនមែនតែគណបក្សសមរង្ស៊ីទេ គឺមានគណបក្សសិទ្ធិមនុស្សមួយទៀតក៏បានធ្វើយុទ្ធនាការប្រមូលស្នាមមេដៃផងដែរ ដើម្បីយកទៅបង្ហាញអន្តរជាតិឱ្យឃើញថាគណបក្សប្រជាជនតាមរយៈឧបករណ៍របស់គេ គឺ គ.ជ.ប នេះ គេបានលុបឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតច្រើនណាស់ ហើយស្នាមមេដៃទាំងអស់ហ្នឹងយើងបានដាក់ក្នុងវិបសាយរបស់យើងដែលទោះជាប្រទេសណាក៏ដោយក៏គេអាចមើលឃើញដែរ។

ទន្ទឹមនេះ លោក *សម រង្ស៊ី* នៅបានអំពាវនាវថា "*បើបងប្អូនណាមានភស្តុតាងដែលបានទទួលទម្រង់១០១៨ក្លែងក្លាយ គឺសុំយកទម្រង់១០១៨ក្លែងក្លាយនោះមកប្រគល់ឱ្យខ្ញុំផ្ទាល់ ដែលកន្លងមកខ្ញុំបានទទួលច្រើនណាស់ ខ្ញុំសូមថ្លែងអំណរគុណចំពោះបងប្អូនដែលបានមកជួបខ្ញុំផ្ទាល់ នៅទីស្នាក់ការធំនៃគណបក្សសមរង្ស៊ី។ ហើយខ្ញុំសុំរំលឹកម្តងទៀតចំពោះបងប្អូនដែលអញ្ជើញមកពីទីជិតឆ្ងាយ ខ្ញុំសូមសម្តែងអំណរគុណអស់ពីដួងចិត្ត ហើយសុំជូនរង្វាន់ដល់បងប្អូនដែលយកទម្រង់១០១៨ក្លែងក្លាយមួយសន្លឹក គឺខ្ញុំនឹងជូនរង្វាន់៥០ដុល្លារស្មើនឹង២០ម៉ឺនរៀល* "។

ក្នុងនោះលោក *សម រង្ស៊ី* ក៏បានអំពាវនាវទៅដល់ប្រធានភូមិ, អនុប្រធានភូមិទូទាំងប្រទេស ឱ្យចូលមកបំភ្លឺពីការធ្វើទម្រង់១០១៨ក្លែងក្លាយដែលកន្លងមកមេឃុំ និងចៅសង្កាត់ក៏មានដែរ សុទ្ធតែមកពីគណបក្សប្រជាជនទាំងអស់ដែលគេស្រឡាញ់យុត្តិធម៌និងសុទ្ធតែជាមន្ត្រីមូលដ្ឋានដែលមេៗគណបក្សប្រជាជនមិនសូវឃើញបានចូលមកលាតត្រដាងពីពុតត្បុតដ៏អាក្រក់របស់មេដឹកនាំខ្លួនប្រាប់លោក *សម រង្ស៊ី* គ្មានចន្លោះឡើយ។

ជាក់ស្តែងមន្ត្រីក្រុមការងារគណបក្សប្រជាជនប្រចាំខេត្តកំពង់ចាមម្នាក់បានអះអាងតាមកម្មវិធីពន្លឺភ្លើងទៀនជាសាធារណៈថា ការបោះឆ្នោតកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨កន្លងទៅនេះ គឺមានភាពមិនប្រក្រតីមិនយុត្តិធម៌ដូចជាមានការគំរាមបំភិតបំភ័យ ការរំលោភសិទ្ធិមនុស្សនិងបញ្ហាទម្រង់១០១៨ក្លែងក្លាយដែលគេហៅថាឈ្មោះខ្មោច។

ទាក់ទិននឹងបញ្ហាទម្រង់១០១៨ក្លែងក្លាយត្រូវបានមន្ត្រីគណបក្សប្រជាជនរូបនោះអះអាងថា មានច្រើនសន្លឹកសន្ធាប់ណាស់ ពោលគឺមេឃុំ មេភូមិជាដើម បានជួបជុំគ្នា៣-៤ថ្ងៃមុនការបោះឆ្នោត ដើម្បីរៀបចំគម្រោងធ្វើទម្រង់១០១៨ ឬឈ្មោះខ្មោច និងករណីផ្សេងៗទៀត។

មន្ត្រីគណបក្សប្រជាជនបានលើកឡើងថា "*ករណីពិសេសគឺ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ មានមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនបានចុះទៅពង្រឹងការងារបក្សនៅស្រុកមេមត់នោះ គឺលោក អ៊ុក ប៊ុនឈឿន បានឱ្យមន្ត្រីថ្នាក់ក្រោមធ្វើទម្រង់១០១៨ក្លែងក្លាយ និងករណីផ្សេងៗទៀត* "។

បានសេចក្តីថា ពុតត្បុតដ៏អាក្រក់របស់គណបក្សប្រជាជននិងគ.ជ.ប ចាប់ផ្តើមបែកជាអួរហួរជាស្ទឹងហើយ។ ដូច្នេះសហគមន៍អន្តរជាតិ នឹងមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដ៏អយុត្តិធម៌នេះជាដាច់ខាត៕

**តមកពីទំព័រ១ ម**

គួរបញ្ជាក់ថា ប្រជាពលរដ្ឋមានគ្នាប្រមាណជាង១០០នាក់ដែលសុទ្ធសឹងតែជាអ្នករស់នៅតំបន់បឹងកក់បានទៅប្រមូលផ្តុំគ្នានៅមុខសាលាក្រុងភ្នំពេញកាលពីព្រឹកថ្ងៃច័ន្ទ ទី០១ ខែកញ្ញា និងបានប្រគល់ញត្តិស្នើសុំឱ្យសាលាក្រុងផ្អាកការបូមខ្សាច់លុបបឹងកក់ដោយក្រុមហ៊ុនស៊ូកាគូអ៊ីន។ ពិសេសគឺប្រជាពលរដ្ឋទាំងនោះបានទាមទារឱ្យក្រុមហ៊ុនស៊ូកាគូអ៊ីនចេញមុខមកដោះស្រាយបញ្ហាប្រាក់សំណងជាមួយប្រជាពលរដ្ឋដោយផ្ទាល់ថែមទៀតផង។

តំណាងប្រជាពលរដ្ឋដែលកំពុងធ្វើការតវ៉ានៅមុខសាលាក្រុងភ្នំពេញកាលពីថ្ងៃច័ន្ទនោះបានអះអាងថា "*ប្រជាពលរដ្ឋទាំងអស់មិនទទួលយកប្រាក់សំណងដែលក្រុមហ៊ុនបានប្រគល់ឱ្យតាមរយៈសាលាក្រុងភ្នំពេញចំនួន៨ពាន់ដុល្លារក្នុងមួយគ្រួសារនោះទេនិងបានទាមទារឱ្យក្រុមហ៊ុនដោះស្រាយសំណងសមរម្យស្របតាមតម្លៃទីផ្សារ* "។

តំណាងប្រជាពលរដ្ឋដដែលនេះបានឱ្យដឹងទៀតថា ប្រជាពលរដ្ឋដែលនាំគ្នាធ្វើការតវ៉ាទាំងអស់នោះគឺបណ្តាលមកពីមិនមានការទុកចិត្តចំពោះដំណោះស្រាយរបស់សាលាក្រុងឡើយ។

ប្រជាពលរដ្ឋបានបញ្ជាក់យ៉ាងដូច្នេះថា "*សាលាក្រុងគ្រាន់តែមានតួនាទីមួយទទួលស្គាល់ថាប្រជាពលរដ្ឋបានព្រមព្រៀងហើយ។ ព្រោះប្រជាពលរដ្ឋយល់ឃើញថា ជួនកាលក្រុមហ៊ុនគេឱ្យពីរម៉ឺន ឬ៣ម៉ឺនក្នុងមួយគ្រួសារតែខាងសាលាក្រុងប្រកាសថា គេឱ្យ៨ពាន់ដុល្លារ តើឱ្យប្រជាពលរដ្ឋទុកចិត្តយ៉ាងម៉េចបាន* "?

តំណាងប្រជាពលរដ្ឋម្នាក់ទៀតបាននិយាយដោយត្រង់ៗថា "*ខ្ញុំចង់ឱ្យក្រុមហ៊ុនជួបជាមួយពួកយើងដោយផ្ទាល់ដើម្បីចរចាគ្នារកតម្លៃសមស្របមួយ ព្រោះយើងមើលឃើញថា វាមិនត្រឹមត្រូវទាល់តែសោះដែលក្រុមហ៊ុនផ្តល់សំណងដូចៗគ្នាដោយមិនគិតថា តើអ្នកណាផ្ទះធំ ឬផ្ទះតូចនោះ* "។

ថ្វីបើខាងសាលាក្រុងភ្នំពេញបានទទួលញត្តិតវ៉ានោះពីប្រជាពលរដ្ឋរស់នៅបឹងកក់ហើយក្តីក៏សាលាក្រុងមិនទាន់បានធ្វើការដោះស្រាយភ្លាមៗដែរ ពោលគឺគេពន្យារពេលដល់ទៅសប្តាហ៍ក្រោយឯណោះ។ហើយការបូមខ្សាច់ដាក់បឹងកក់ដោយក្រុមហ៊ុនស៊ូកាគូអ៊ីនរបស់ឧកញ៉ា *ឡាវ ម៉េងឃីន* ស្វាមីមេឈ្មួញស៊ីឈើ *ជឹង សុភាព* ហៅយាយភូនោះនៅតែបន្តឥតឈប់ឈរ ដែលធ្វើឱ្យទឹកបឹងកក់ជន់លិចផ្លូវ និងផ្ទះសម្បែងប្រជាពលរដ្ឋបណ្តើរៗហើយ។

ក្រុមមន្ត្រីសិទ្ធិមនុស្សបានវាយតម្លៃថា វាមិនសមស្របនោះទេចំពោះការឆ្លើយតបរបស់សាលាក្រុងភ្នំពេញត្រូវអូសបន្លាយពេលវេលាដល់ទៅមួយសប្តាហ៍ខណៈដែលក្រុមហ៊ុននៅតែបន្តសកម្មភាពបូមខ្សាច់លុបបឹងកក់យ៉ាងដូច្នេះនោះ។

មន្ត្រីផ្នែកស៊ើបអង្កេតនៃអង្គការសិទ្ធិមនុស្សអាដហុកបានថ្លែងថា "*ប្រការដែលប្រជាពលរដ្ឋមកតវ៉ានេះ គឺចង់ឱ្យក្រុមហ៊ុនបញ្ឈប់ការបូមខ្សាច់ដាក់បឹងកក់ តែខាងសាលាក្រុងមិនបានហាមឃាត់ទេ ហើយបែរជានិយាយថា បូមនៅតែបូមដដែល។ ដូច្នេះវាដូចជាគ្មានដំណោះស្រាយអ្វីទាល់តែសោះសម្រាប់ការតវ៉ារបស់ប្រជាពលរដ្ឋនៅតំបន់បឹងកក់នោះ* "។

គួរបញ្ជាក់ផងដែរថា រដ្ឋាភិបាល*ហ៊ុន សែន* បានអនុញ្ញាតឱ្យក្រុមហ៊ុនស៊ូកាគូអ៊ីនអភិវឌ្ឍន៍តំបន់បឹងកក់ក្នុងរយៈពេល៩៩ឆ្នាំលើផ្ទៃដីទំហំជិត១៣៣ហិកតា។ ហើយការអនុញ្ញាតនេះត្រូវបានក្រុមអង្គការសិទ្ធិមនុស្សរិះគន់ថាបានរំលោភលើច្បាប់ភូមិបាលឆ្នាំ២០០១ ដែលថាការផ្ទេរបឹងជាកម្មសិទ្ធិរបស់រដ្ឋទៅឱ្យឯកជនគឺមិនត្រូវហួសពីរយៈពេល១៥ឆ្នាំឡើយ។

តាមពិតទៅការអភិវឌ្ឍន៍តំបន់បឹងកក់តាមវិធីចាក់ដីលុបបឹងដូច្នេះត្រូវបានសាធារណមតិជាទូទៅរិះគន់យ៉ាងកងរំពងតាំងពីដើមទីមកម្ល៉េះពិសេសគឺប្រជាពលរដ្ឋដែលជាម្ចាស់ទីលំនៅតែ

**តទៅទំព័រ៣ ម**

**តមកពីទំព័រ១ ក**

ត្រា កំពុងរងសម្ពាធគាបសង្កត់ឱ្យចុះចេញពីតំណែងនោះ នៅកម្ពុជាឯណោះនាយករដ្ឋមន្ត្រី ហ៊ុន សែននៃគណបក្សប្រជាជនក៏កំពុងតាមដានស្ថានការណ៍វិវឌ្ឍន៍នៅប្រទេសសៀមដោយកង្វល់ព្រួយខ្លាំងដែរ។ នោះក៏ដោយសារតែគេដឹងថា សាម៉ាក់ជាកូនអុករបស់ ថាក់ស៊ីន ដែលរងការចោទប្រកាន់ថា ធ្វើនយោបាយដើម្បីនាំ ថាក់ស៊ីន វិលត្រឡប់ចូលកាន់អំណាចវិញ ដូច្នេះក៏បង្កើតឱ្យមានការប្រឆាំងខ្លាំងក្លាក្លាយជាភាពវឹកវរនយោបាយនៅក្នុងប្រទេសសៀមសព្វថ្ងៃ។

ហេតុអ្វីបានជានាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន សែន នៅតែមានសេចក្តីព្រួយ បារម្ភ ? នេះក៏ព្រោះតែថា បើ សាម៉ាក់ ស៊ុនដារ៉ាវេត ត្រូវធ្លាក់ចេញពីតំណែងនាយករដ្ឋមន្ត្រី នោះអ្វីៗជាកិច្ចសន្យាសម្ងាត់រវាង ហ៊ុន សែន ជាមួយ ថាក់ស៊ីន នោះក៏នឹងបែកធ្លាយដែរ។

កាលក្នុងអំឡុងខែមេសា និង មិថុនា ហ៊ុន សែន បានទទួល ថាក់ស៊ីន ស៊ីណាវ៉ាត្រា នាយករដ្ឋមន្ត្រីធ្លាក់ចេញពីតំណែង ហើយក៏មានកិច្ចសន្យាសម្ងាត់បិទបាំងរវាងគ្នា ដែលហ៊ុន សែន បានប្រកាសបង្អើបត្រឹមតែពាក្យថា មានកិច្ចព្រមព្រៀងវិនិយោគទុនរកស៊ីជាមួយ ថាក់ស៊ីន ដែលនឹងចំណាយលុយប្រមាណជាង១០លានដុល្លារធ្វើការអភិវឌ្ឍន៍នៅតំបន់ខេត្តកោះកុង និងខេត្តព្រះវិហាររបស់ខ្មែរ។ រឿងនេះរឹតតែដុតកំដៅពួកអ្នកនយោបាយ និងពួកអ្នកប្រឆាំងនៅប្រទេសសៀម ដោយបង្កើនកម្លាំងសម្ពាធគាបសង្កត់លើរដ្ឋាភិបាល សាម៉ាក់ ស៊ុនដារ៉ាវេត ដើម្បីបិទផ្លូវ ថាក់ស៊ីន មិនឱ្យចូលធ្វើនយោបាយផង និងដើម្បីនាំ ថាក់ស៊ីនចូលតុលាការវិនិច្ឆ័យរឿងបទល្មើសពុករលួយកេងបន្លំប្រាក់ជាតិរាប់ពាន់លានដុល្លារផង។

ពុំមាននរណាដឹងថាហ៊ុនសែនបានចុះកិច្ចសន្យាសម្ងាត់ជាមួយ ថាក់ស៊ីន ស៊ីណាវ៉ាត្រា ជុំវិញរបស់ដែលហៅថា អភិវឌ្ឍន៍តំបន់ខេត្តកោះកុង និងតំបន់ប្រាសាទព្រះវិហារនៃទឹកដីកម្ពុជាក្នុងទឹកប្រាក់ជាង១ពាន់លានដុល្លារនោះ ហ៊ុន សែន បាននឹងបានផលចំណែកប៉ុន្មានភាគរយក្នុងការយល់ព្រមជាមួយ ថាក់ស៊ីន នោះទេ។ ហើយក្នុងករណីដែលគម្រោងនេះបរាជ័យ ជាពិសេសករណីដែល សាម៉ាក់ ស៊ុនដារ៉ាវេត ត្រូវបង្ខំចិត្តលាលែងពីតំណែងនាយករដ្ឋមន្ត្រីនោះ កិច្ចសន្យាសម្ងាត់រវាង ហ៊ុន សែន និង ថាក់ស៊ីន ស៊ីណាវ៉ាត្រា ជុំវិញរបស់ដែលហៅថា អភិវឌ្ឍន៍ដីខ្មែរទាំងពីរកន្លែង ដែលសៀមប៉ុនប៉ងចង់យកតាំងពីច្រើនទសវត្សរ៍មកហើយនោះ ក៏នឹងជាផែនការបរាជ័យ។

ហើយសម្រាប់ ហ៊ុន សែន គេជឿថា មិនមែនគាត់នេះក្លាហានតែរឿងបាត់បង់ផលប្រយោជន៍ដែលខ្លួនអាចត្រូវបានប្រសិនបើ ថាក់ស៊ីនអនុវត្តន៍បានសម្រេចនូវផែនការអភិវឌ្ឍន៍លុយជាង១ពាន់លានដុល្លារនៅខេត្តកោះកុងនិងតំបន់ប្រាសាទព្រះវិហារនោះទេ ប៉ុន្តែគេជឿថា ហ៊ុន សែន ក៏ខ្លាចផងដែរនូវការធ្លាយរឿងអាស្រូវជាប់ទាក់ទិនជាមួយនឹង ថាក់ស៊ីន ស៊ីណាវ៉ាត្រា។

ដូច្នេះបានជាគេឮមន្ត្រីរដ្ឋាភិបាលកម្ពុជា ទាំងនាយករដ្ឋមន្ត្រី ហ៊ុន សែន ខ្លួនឯង ក៏ដូចជាអ្នកនាំពាក្យនៃរដ្ឋាភិបាលគណបក្សប្រជាជនចេះតែលើកនិយាយក្នុងអត្ថន័យរបៀបជួយការពាររដ្ឋាភិបាល សាម៉ាក់ ស៊ុនដារ៉ាវេត ផង ហើយរិះគន់ពួកអ្នកនយោបាយប្រឆាំងនឹងរដ្ឋាភិបាលសៀមផង ក្នុងបំណងរបៀបការពារជាប្រយោលនូវផលប្រយោជន៍ជាមួយ ថាក់ស៊ីន ក៏ដូចជាដំណើរផ្លូវរបស់ ថាក់ស៊ីន វិលត្រឡប់ទៅរកអំណាច ដែលឥឡូវត្រូវចប់ទៅហើយនោះ។

អ្វីដែលគេអាចយល់បានអំពីកង្វល់ដ៏ធំរបស់រដ្ឋាភិបាលហ៊ុន សែន ជាពិសេសនោះ គឺនាយករដ្ឋមន្ត្រីនេះផ្ទាល់តែម្តងនៅត្រង់ថា ហ៊ុន សែន កាលក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីថ្ងៃសុក្រ សប្តាហ៍កន្លងទៅ គាត់នេះបានចេញសេចក្តីណែនាំឱ្យមេការទូតកម្ពុជា ហោ ណាំហុង រកគ្រប់វិធី និងមធ្យោបាយទាក់ទងឱ្យមានការបន្តការចរចាជាថ្មីជាមួយរដ្ឋាភិបាលសៀមជុំវិញតំបន់ប្រាសាទព្រះវិហារដែលសៀម បានលើកទាហានចូលកាន់កាប់ដីខ្មែរតាំងពីពាក់កណ្តាលខែកក្កដាមកនោះ។ ហេតុអ្វីបានជា ហ៊ុន សែន រុញ ហោ ណាំហុង ឱ្យប្រឹងទាក់ទងសុំចរចាជាមួយរដ្ឋាភិបាលសៀម ក្នុងពេលដែលប្រទេសនេះកំពុងមានវិបត្តិនយោបាយធ្ងន់ធ្ងរនោះ ? នេះមកពី ហ៊ុន សែន ព្រួយ បារម្ភអំពីថា បើ សាម៉ាក់ ធ្លាក់ពីអំណាចទៅ មិនទាន់បានធ្វើការចរចាជាមួយគ្នានោះហ៊ុន សែនក៏នឹងត្រូវរណ្ហកដោយសារនយោបាយចុះហត្ថលេខាលើអនុស្សារណៈជាមួយរដ្ឋាភិបាលសៀមរឿងទឹកដីក្បែរព្រំដែន។ លើសពីនេះទៅទៀត គឺ ហ៊ុន សែន ដឹងខ្លួនថា នយោបាយការទូតរបស់ខ្លួនចាញ់ប្រៀបសៀម ជាគ្រោះអាក្រក់នោះ ប្រទេសខ្មែរអាចបាត់បង់ទឹកដីមួយចំនួនតាមខ្សែបន្ទាត់ព្រំដែនដោយការបន្តកាន់កាប់របស់ទាហានសៀមឈ្លានពាន។

ហ្នឹងហើយដែលថា នៅបាងកក រដ្ឋាភិបាលសាម៉ាក់ស៊ុនដារ៉ាវេត ភ័យខ្លាចត្រូវគេរំលាយ ហើយនាយករដ្ឋមន្ត្រីសៀមធ្លាក់ចេញពីតំណែង ឯនៅកម្ពុជាវិញ ហ៊ុន សែន គណបក្សប្រជាជន ក៏មានការព្រួយ បារម្ភអំពីការបាត់បង់ឱកាសនៃផលប្រយោជន៍កិច្ចការសម្ងាត់ចុះហត្ថលេខាជាមួយ ថាក់ស៊ីន នាយករដ្ឋមន្ត្រីធ្លាក់ពីតំណែង ដែលរងការចោទប្រកាន់ដោយជនជាតិសៀមថា ជាមនុស្សនៅពីក្រោយខ្នង សាម៉ាក់ស៊ុនដារ៉ាវេត។ បើ សាម៉ាក់ ស៊ុនដារ៉ាវេត ធ្លាក់ពីតំណែងនោះរដ្ឋាភិបាល ហ៊ុន សែន ក៏មានបញ្ហាធំៗ ទាំងបញ្ហាផលប្រយោជន៍របស់ខ្លួនជាមួយ ថាក់ស៊ីន ក៏ដូចជា បញ្ហាបង្កើនវិបត្តិឱ្យប្រទេសជាតិស្ថិតក្នុងគ្រោះបាត់បង់ទឹកដីតាមបណ្តោយព្រំដែនជាមួយសៀមជាមិនខាន៕